# មណ្ឌលចត្តាឡីស័ក៖ អ្វីដែលអ្នកត្រូវដឹង

## ប្រសិនបើអ្នកត្រូវបានគេធ្វើចត្តាឡីស័ក អ្នកអាច៖

- ទទួលបានអាហារ ទឹកស្អាត និងសម្ភារៈដែលជាតម្រូវការចាំបាច់
- ស្នើសុំព័ត៌មានអំពីសិទ្ធិ ការរក្សាការសម្ងាត់ ការប្រឹក្សាយោបល់
- ទទួលបានឯកជនភាពដោយសមស្របដូចជានៅកន្លែងបន្ទប់ទឹក និងកន្លែងស្នាក់ដែលមានសុវត្ថិភាពជាដើម
- ស្នើសុំសេវាវេជ្ជសាស្ត្រ
- ស្នើសុំសេវាគាំទ្រផែនការគ្រួសារ ការពន្យាកំណើត
- ស្នើសុំការគាំទ្រពីបុគ្គលិកសង្គមកិច្ច
- រក្សាទំនាក់ទំនងជាមួយ កូន/ ឪពុកម្តាយ / អ្នកមើលថែ/សមាជិកគ្រួសារ ឬអ្នកធ្វើការងារសង្គម
- ទទួលបានការការពារពីរាល់ទម្រង់នៃអំពើហិង្សា និងការរើសអើង
- ស្នើសុំព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹង

## កុមារ គួរទទួលបានការការពារក្នុងកម្រិតខ្ពស់ និងគួរទទួលបាន៖

- មានឪពុកម្តាយ សាច់ញាតិ ឬអាណាព្យាបាលមើលថែ ឬ ស្នាក់នៅជាមួយនឹងអ្នកដែលគាត់ជឿទុកចិត្ត
- ការពិគ្រោះយោបល់អំពីសុខភាព ការអប់រំ ការថែទាំ / ការថែទាំជំនួស និងសុខុមាលភាព
- ព័ត៌មានជាភាសាដែលពួកគេងាយយល់
- ការគាំទ្រផ្នែកចិត្តសង្គម និងការព្យាបាលពីអ្នកឯកទេស
- កន្លែងសមស្រប សម្ភារៈ អាហារ កញ្ចប់អនាម័យ រក្សាឯកជនភាព ការអប់រំ និងសម្ភារៈកំសាន្ត
- កុមារបែកពីឪពុកម្តាយ ឬមានអាណាព្យាបាល មានសិទ្ធិទទួលបានការគាំទ្រ មើលថែទាំ និង ទំនាក់ទំនងទៅគ្រួសារ
- ស្នើសុំការគាំទ្រពីបុគ្គលិកសង្គម ឬមន្ត្រីបង្គោលនៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- ជំរើសជួបជុំគ្រួសារតាមតម្រូវការ ឬការមើលថែតាមគ្រួសារ នៅពេលដែលកុមារត្រូវបានអនុញ្ញាតិអោយផ្លាស់ចេញពីមណ្ឌលចត្តាឡីស័ក

**ប្រសិនបើអ្នកប្រឈម** ឬមើលឃើញករណីអំពើហិង្សា ការរំលោភបំពាន ឬអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ សូមផ្តល់ព័ត៌មានដល់មន្ត្រីបង្គោលនៃមជ្ឈមណ្ឌលចត្តាឡីស័ក អ្នកអាចស្នើសុំ៖

- ស្វែងរកជំនួយពីគ្រូពេទ្យ និយាយជាមួយនឹងអ្នកឯកទេស (ភេទដូចគ្នា) ដើម្បីទទួលការផ្តល់ប្រឹក្សា និងការគាំទ្រផ្លូវចិត្ត
- នៅដោយឡែកពីជនដែលប្រព្រឹត្តហិង្សា
- រក្សាការសម្ងាត់

### សូមទូរសព្ទទៅ៖

- ☞ **ក្រសួងសុខាភិបាល** លេខ **១១៥** សម្រាប់ព័ត៌មានជំងឺកូវីដ ១៩
- ☞ **នគរបាល** លេខ **១២៨៨** សម្រាប់ការរាយការណ៍ករណីរំលោភបំពាន ការបៀតបៀន និងការកេងប្រវ័ញ្ច
- ☞ **បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា** លេខ **១២៨០** សម្រាប់ការប្រឹក្សាយោបល់
- ☞ **អង្គការ TPO** លេខ **០១៧ ២២២ ៣៧២ / ០៨៩ ៦៦៦ ៣២៥ / ០៩៧ ៩១១១ ៩១៨**
  សម្រាប់ការគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រចាប់ពីម៉ោង ៨ ព្រឹក ដល់១០ យប់

សហការជាមួយ៖

ក្រសួងសុខាភិបាល

គាំទ្រដោយ៖

USAID FROM THE AMERICAN PEOPLE · unicef for every child · UN WOMEN · UNFPA · UNITED NATIONS HUMAN RIGHTS · Save the Children